ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អន្លង់វាលព្រលូងលួងចិត្ត
# រយៈពេល ៣ ឆ្នាំ ( ២០១៨ - ២០២០ )

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ អន្លង់វាលព្រលូងលួងចិត្ត |
| ភូមិ | ៖ អំពិលទឹក |
| ឃុំ | ៖ កំពង់ចាម |
| ស្រុក | ៖ សំបូរ |
| ខេត្ត | ៖ ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អន្លង់វាលព្រលូងលួងចិត្ត
## រយៈពេល ៣ ឆ្នាំ ( ២០១៨ - ២០២០ )

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | អន្លង់វាលព្រលូងលួងចិត្ត |
| ភូមិ | ៖ | អំពិលទឹក |
| ឃុំ | ៖ | កំពង់ចាម |
| ស្រុក | ៖ | សំបូរ |
| ខេត្ត | ៖ | ក្រចេះ |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**១-ស្ថានភាពទូទៅ**......................................................................................................................៣
**២-អំពីប្រជាសាស្ត្រនិងសេដ្ឋកិច្ចសង្គម**..................................................................................................៤
ក-ប្រជាសាស្ត្រ..............................................................................................................................៤
ខ-មុខរបរ......................................................................................................................................៤
**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងសហគមន៍**....................................................៥
ក-ទីតាំង........................................................................................................................................៥
ខ-ដែននេសាទ.................................................................................................................................៥
គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស....................................................................................................៥
ឃ-ធនធានជលផល..........................................................................................................................៥
**៤-ការធ្វើនេសាទ**..........................................................................................................................៦
ក-អ្នកនេសាទ..................................................................................................................................៦
ខ-ឧបករណ៍នេសាទ.........................................................................................................................៦
គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ..................................................................................................៦
**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**.................................................................................................៧
ក-ទស្សនវិស័យ.................................................................................................................................៧
ខ-គោលបំណង..................................................................................................................................៧
គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.............................................................................................៨
គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ..............................................................................................៨
គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍.........................................................................................៩
គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ.................................................................................១០
គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត.........................................................................................១១
គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ....................................................................................១២
គ៦-ផែនការផ្សព្វផ្សាយ.....................................................................................................................១៣
គ៧-ផែនការបណ្តុះបណ្តាល.................................................................................................................១៤
គ៨-ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍...........................................................................................១៥
គ៩-ផែនការកែលម្អដែននេសាទ..........................................................................................................១៦
គ១០-ផែនការអភិវឌ្ឍវារីវប្បកម្ម.......................................................................................................១៦
គ១១-ផែនការមុខរបរចិញ្ចឹមជីវិត.......................................................................................................១៧
ឃ.ផែនការយុទ្ធសាស្ត្រ.......................................................................................................................១៨
-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ.........................................................១៩
-តារាងកម្មវិធីការងារ.........................................................................................................................២២

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

**១-ស្ថានភាពទូទៅ**

សហគមន៍នេសាទអន្លង់វាលព្រលូងលួងចិត្ត ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ ដោយអង្គការ CAA/Oxfam Australia បន្ទាប់មកអង្គការ WWF បានបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១១ និងបានចុះកិច្ចព្រមព្រៀងតំបន់នេសាទសហគមន៍រវាងខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទ អាណត្តិទី១ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ និងបានបន្តចុះកិច្ចព្រមព្រៀងតំបន់នេសាទសហគមន៍ អាណត្តិ ទី២នៅថ្ងៃទី២៧ កញ្ញា ឆ្នាំ២០១៦ ។

សហគមន៍នេសាទអន្លង់វាលព្រលូងលួងចិត្ត មានទីតាំងស្ថិតនៅក្នុងភូមិអំពិលទឹក ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ ដែលមានសមាជិកសរុបចំនួន ១៥៦ នាក់ ស្រីចំនួន ៦៨ នាក់ និងមានគណៈកម្មការចំនួន ៩ នាក់ ស្រីចំនួន ០២ នាក់ ។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ៣២៤ គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

**១- អង្គការ CAA/Oxfam Australia**

- បានបង្កើតតំបន់អភិរក្សត្រីមេពូជ និងសត្វផ្សោត និងដាក់ស្លាកសញ្ញាចំនួន ០៥ ស្លាក
- បានបង្កើតក្រុមល្បាតសហគមន៍នេសាទ
- ធនាគារស្រូវ ធនាគារក្របី ក្រុមសន្សំប្រាក់
- សាងសង់សាលារៀន ផ្ទះគ្រូ
- គម្រោងអនាម័យទឹកស្អាត បង្គន់ អនាម័យចម្រុះ។

**២- អង្គការ CRDT**

បានបង្កើតឱ្យមាន៖

- ក្រុមសន្សំប្រាក់
- បណ្តុះបណ្តាលការដាំដំណាំ សិប្បកម្មម្ហូប
- គណៈកម្មការទេសចរណ៍ធម្មជាតិ
- ស្រះចិញ្ចឹមត្រី ចិញ្ចឹមសត្វមាន់ ទា ជ្រូក។

**៣- អង្គការ WWF**

- ជួយរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទឡើងវិញ
- បានជួយរៀបចំឯកសារដើម្បីចុះបញ្ជីសហគមន៍នេសាទជាផ្លូវការដូចជា៖
- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ផែនទីសហគមន៍នេសាទដោយមាននិយាមការច្បាស់លាស់
- រៀបចំឯកសារចុះកិច្ចព្រមព្រៀង ផែនការគ្រប់គ្រងសហគមន៍នេសាទដែលទទួលស្គាល់ដោយថ្នាក់ជាតិ

- បានឧបត្ថមទូកកាណូតមួយគ្រឿង អាវពោងចំនួន១០ អាវភ្លៀងចំនួន៥ និងពិលបំភ្លឺពេលយប់ចំនួន២
- បានរៀបចំក្រុមល្បាត និងផែនការចុះល្បាតប្រចាំខែ
- បានធ្វើបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍ចំនួន ៤ កន្លែង
- បានធ្វើក្បួនស្លាកសញ្ញាបណ្តែតទឹកដាក់កន្លែងអន្លង់អភិរក្សចំនួន៦ស្លាក
- បានបង្កើតកម្មវិធីតាមដានផលចាប់ត្រីប្រចាំថ្ងៃ
- បានបង្កើតឆ្មាំទន្លេការពារតំបន់អភិរក្សសត្វផ្សោតនិងអន្លង់ត្រីមេពូជ។

បញ្ហាប្រឈម ៖

នៅមុនពេលបង្កើតសហគមន៍នេសាទ តែងតែមានបទល្មើសនេសាទកើតមាននៅក្នុងតំបន់សហគមន៍នេសាទ និងបណ្តាលឱ្យធនធានជលផលមានការថយចុះជាលំដាប់។ ប៉ុន្តែបន្ទាប់ពីបានបង្កើតសហគមន៍នេសាទមក គណៈកម្មការសហគមន៍បានសហការជាមួយប៉ូលីសប៉ុស្តិ៍ អាជ្ញាធរភូមិ ឃុំ ស្រុក មន្ត្រីជលផល និងឆ្មាំទន្លេចុះល្បាតនិងបង្ក្រាបបទល្មើស ធ្វើឱ្យបទល្មើសជលផលមានការថយចុះ និងធនធានជលផល និងផ្សោតមានការកើនឡើងវិញ ។

ទន្ទឹមនឹងនេះ ក៏នៅមានបទល្មើសនេសាទមកពីអ្នកខាងក្រៅសហគមន៍នេសាទលួចធ្វើនេសាទនៅកន្លែងអភិរក្សជាពិសេសនៅពេលយប់ ។ ដោយសហគមន៍នេសាទនៅមានការខ្វះខាតប្រេងសម្រាប់ចាក់កាណូតចុះយាមល្បាតឱ្យបានទៀងទាត់ខ្វះទីស្នាក់ការសម្រាប់បំពេញការងារខ្វះសំភារៈសម្រាប់ចុះល្បាត។ ម៉្យាងវិញទៀតគណៈកម្មការសហគមន៍នេសាទ ពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ ហើយសមាជិកសហគមន៍នេសាទក៏នៅពុំទាន់មានការយល់ដឹងនិងចូលរួមការងារសហគមន៍ឱ្យបានសស្រាក់សស្រាំផងដែរ ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក -ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ១,៤៥៦ នាក់ ប្រុសចំនួន ៧៣១ នាក់ ស្រី ៧២៥ នាក់ ក្នុងនោះជនជាតិខ្មែរ១០០%

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១៩ នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ១៤ នាក់ ស្រី ៨ នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ០៨ នាក់ ស្រី ០៦ នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ០៧ នាក់ ស្រី ៣ នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ០៥ នាក់ ស្រី ០៤ នាក់

- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន៣៨៣នាក់ប្រុសមានចំនួន២៤៧នាក់និងស្រីមានចំនួន១៣៦ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ២២៦ នាក់ ស្រី ១០៧ នាក់ មធ្យមសិក្សា ៥៦ នាក់ ស្រី៣១ នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាមាន០៨នាក់ ស្រី០៣នាក់។

ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

-ធ្វើស្រែវស្សាចំនួន ២៤៦ គ្រួសារ ទំហំ ៨៤ ហិកតា (៩០%)

-ធ្វើនេសាទជាលក្ខណៈគ្រួសារ ចំនួន ១៨០ គ្រួសារ (៧០%)

-ធ្វើចំការចំនួន ១៨០ គ្រួសារ ទំហំ ៦៧ ហិកតា( ដាំដំឡូង ៣០% , សណ្តែក ៧០ %)

-ធ្វើជាងផ្ទះចំនួន ០២ គ្រួសារ

-ជាងធ្វើទូក ចំនួន ០១ គ្រួសារ

-សិប្បកម្មចំនួន ០១ គ្រួសារ

-លក់ដូរចំនួន ១១ គ្រួសារ

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក-ទីតាំង

កន្លែងនេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្ត ស្ថិតនៅតាមដងទន្លេមេគង្គលើ មានទំហំ ៥៧១,៨៧ ហិកតា និងមាននិយាមការដូច មានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងជើងទល់នឹងភូមិអូរក្រសាំង ឃុំបឹងចារ

-ខាងត្បូងទល់នឹងភូមិកំពង់ក្របី

-ខាងកើតទល់នឹងភូមិអំពិលទឹក

-ខាងលិចទល់នឹងភូមិអាជេន។

### ខ-ដែននេសាទ

កន្លែងនេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្ត ស្ថិតនៅតាមដងទន្លេមេគង្គ ដែលមានអន្លង់ កោះ និងព្រៃលិចទឹកដុះរាយនៅតាមមាត់ច្រាំងទន្លេ និងនៅតាមកោះ ។

### គ-តំបន់ដែលបានបង្កើតកន្លែងអភិរក្ស

-អន្លង់អភិរក្សខ្សាច់ស្វាយ ទំហំ ៨,៩៦ ហិកតា

-អន្លង់អភិរក្សតាម៉ាវ ទំហំ ៨,៨៥ ហិកតា

-អន្លង់អភិរក្សវាលព្រលូង ទំហំ ៣១,៧២ ហិកតា។

### ឃ-ធនធានជលផល

- ប្រភេទត្រី ៖

ត្រីក្អែកពូក ក្អែកថ្ម ក្តី ក្អែកបាយ ប៉ាវ៉ាមុខពីរ ខ្យា ទ្រនេល ឆ្លាំង ត្រសក់ ឆ្ពោក ពោរ កែ ប្រា ប្រាកណ្តុរ អំបូង ឆ្តោរ ចង្អែង ឆ្លិន កាហែ ក្រាយ ស្លាត រមាស ដំរី កែស ក្លាំងហាយ ស្ទក់ សណ្តាយ ចេកទុំ កញ្ចុះ រៀល ផ្ទក់ កន្ទុនដីកំបុតច្រមុះ ព្រួល ព្រលូង សារិកាកែវ គ្រុំ អណ្តែង រ៉ស់ ក្រាញ់ រាជ គល់រាំង គល់ព្រិច ស្លឹកឬស្សី ចង្វារ បបែល ផ្សោត ល្មិច កន្ធាយ ក្រពើ អណ្តើក ពស់ត្រី ពស់ព្រលិត អន្ទង់ ខ្ទឹង ឆ្លូញ ផ្ទោង ក្រពាត់ កន្ត្រង់ប្រេង ត្រីខ្លា ត្រចៀកដំរី អណ្តាតឆ្កែពុកមាត់ឆ្មា ប្រម៉ា ស្តង់ ក្រុស កញ្ជ្រូក កំភ្លាញ ច្អុក បង្កង កំពិស កង្កែប ខ្នាន់ គជ្រា កន្ត្រប់ ខ្យាន ខ្យង ខ្ចៅ។

- ប្រភេទព្រៃលិចទឹក ៖

ដើមត្រស់ រាំង ឃ្លេ រៃ អណ្តែង អញ្ចែង អញ្ចៃ ក្តុល ល្វា ធ្នា ព្រីងទឹក ទន្លា បបុស លាជផ្ទះ កញ្ច្រឹង ផ្តៅមាន់ទឹក សណ្តាន់ ក្របៅ ជ្រោយ អញ្ចាញ បន្លាយូន សំរក ត្រែង ស្មោង ។

## ៤-ការធ្វើនេសាទ

ក-អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍ចំនួន ១៤៤ នាក់ ស្រី ៦១ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន ៤១៧ នាក់ ស្រី ១២៥ នាក់

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ៣៩ នាក់ ស្រី ១៥ នាក់។

ខ.ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សំណាញ់ | វង់ | ៤៥ | ប្រវែង ៥ ម ក្រឡា 0,0២៥ ម | មករា ដល់ មិថុនា |
| បង្កៃ | ផ្លែ | ៧៥ | ផ្លែលេខ ៥-១៧ | មិថុនា ដល់ ធ្នូ |
| លប | លប | ១៥0 | មុខ ១,២ ម បណ្តោយ ២ ម | មិថុនា ដល់ ធ្នូ |
| ចាន់ | ចាន់ | ៣0 | មុខ 0,៤ ម កម្ពស់ ១,៥ ម | មិថុនា ដល់ ធ្នូ |
| មង | ដៃ (៤0ម៉ែត្រ) | ៤៥ | ក្រឡា 0,0២៥ ម-0,0៥0 ម | មករា ដល់ ធ្នូ |
| សន្ទូចរនង | សាង(១00ផ្លែ) | ៤0 | ផ្លែលេខ ៩-១២ | មករា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ១៧ ទូក | ៥00-១000 គីឡូក្រាម | |
| ទូកមានម៉ាស៊ីន | ៣00 គ្រឿង | ៥00-១000 គីឡូក្រាម | ៥ សេះ - ១៨ សេះ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| សន្ទូចរនង | សាង(១00ផ្លែ) | ៣0 | ផ្លែលេខ ១២ | មករា ដល់ ធ្នូ |
| មង | ដៃ (៥0ម៉ែត្រ) | ២0 | ក្រឡា 0,១៤ ម-0,១៥ ម | មករា ដល់ ធ្នូ |
| ប៉ោង | ប៉ោង | ១0 | មុខ 0,៦ ម កម្ពស់ ១៨ ម | មិថុនា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៣ គ្រឿង | ៥00-៨00 គីឡូក្រាម | ៥ សេះ - ១៨ សេះ |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧0 គីឡូក្រាម | ៥0 គីឡូក្រាម | ១២0 គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក-ទស្សនវិស័យ

សហគមន៍នេសាទ **អន្លង់វាលព្រលូងលួងចិត្ត** មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និង ចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ-គោលបំណង

-ចូលរួមគ្រប់គ្រងកន្លែងនេសាទសហគមន៍**អន្លង់វាលព្រលូងលួងចិត្ត**

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍចម្រុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

## គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើង ដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

គោលបំណង ៖
- ដើម្បីកំណត់ចំនួនឧបករណ៍នេសាទក្នុងសហគមន៍ឱ្យបានសមស្រប ជៀសវាងការធ្វើនេសាទហួសកម្រិតផលស្តុក
- ដើម្បីឱ្យសមាជិកសហគមន៍នេសាទ និងអ្នកនេសាទមកពីខាងក្រៅសហគមន៍ធ្វើនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ទីតាំង និងពេលវេលានេសាទ។

ផលរំពឹងទុក ៖
- ត្រីមេពូជ និងសត្វជ្រោត ត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍
- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ ត្រូវបានហាមឃាត់។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | សកម្មភាព | គម្រោងថវិកា (ដុល្លា) | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|---|---|
| | | | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| នៅតាមដងទន្លេមេគង្គនៅខាងក្រៅអន្លង់អភិរក្សសហគមន៍ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់<br>១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទ ឧបករណ៍នេសាទ<br>១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | ២០០/ឆ្នាំ | មករាដល់មិថុនា | សំណាញ់ | ប្រវែង ៥ ម ក្រឡា ០,០២៥ ម | ៤៥ វង់ | |
| | | | មិថុនា ដល់ ធ្នូ | បង្កៃ | ផ្លែលេខ ៥-១៧ | ៧៥ សាង | |
| | | | | លប | មុខ ១,២ ម បណ្ដោយ ២ ម | ១៥០ លប | |
| | | | | ចាន់ | មុខ ០,៤ ម កម្ពស់ ១,៥ ម | ៣០ ចាន់ | |
| | | | មករា ដល់ ធ្នូ | មង | ក្រឡា ០,០២៥ ម-០,០៥០ ម | ៤៥ ដៃ | |
| | | | | សន្ទូចរនង | ផ្លែលេខ ៩-១២ | ១០០ សាង | (១០០ផ្លែ) |

គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍

គោលបំណង ៖ - ដើម្បីបង្ហាញអ្នកនេសាទក្នុងសហគមន៍ និងក្រៅសហគមន៍ឱ្យបានដឹងពីទីតាំងកន្លែងអភិរក្សត្រីមេពូជ និងអភិរក្សសត្វផ្សោត

- ដើម្បីការពារត្រីមេពូជ និងសត្វផ្សោតនៅក្នុងសហគមន៍។

ផលរំពឹងទុក ៖ - ត្រីមេពូជ និងសត្វផ្សោត ត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍

- ការនេសាទនៅកន្លែងអភិរក្ស ត្រូវបានហាមឃាត់។

ផែនការការពារកន្លែងអភិរក្សសហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | សកម្មភាព | គម្រោងថវិកា (ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| អន្លង់អភិរក្សខ្សាច់ស្វាយ | ៨,៩៦ | ២.១-ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ១៥ ស្លាកសម្រាប់៣អន្លង់ | ២០០ | ០១.០១.២០១៨ | ៣០.០៦.២០១៨ | ធ្វើរាល់ឆ្នាំ |
| អន្លង់អភិរក្សតាម៉ារ | ៨,៨៥ | ២.២-បោះបង្គោលព្រំប្រទល់អន្លង់អភិរក្សចំនួន ៤ធ្វើអំពីដែកដែលមានស្លាកសញ្ញាសម្គាល់ និងទង់ជាតិ | ៤០០ | ០១.០១.២០១៨ | ៣០.០៦.២០១៨ | |
| អន្លង់អភិរក្សវាលព្រលូង | ៣១,៧២ | | ២០០ | ០១.០១.២០១៨ | ៣០.០៦.២០១៨ | ធ្វើតែ១ដង សំណើរថវិកាឃុំ |

គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ

គោលបំណង ៖ - ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទមានឧបករណ៍ សំភារៈគ្រប់គ្រាន់ក្នុងការចុះល្បាត និងទប់ស្កាត់បទល្មើសនេសាទគ្រប់ប្រភេទ

- ដើម្បីឱ្យសហគមន៍នេសាទមានទីស្នាក់ការដើម្បីធ្វើការងាររដ្ឋបាល ប្រជុំការងារ ការទំនាក់ទំនង និងរក្សាទុកសំភារៈ និងឯកសារផ្សេងៗ ។

ផលរំពឹងទុក ៖ - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាពខ្ពស់

- សហគមន៍នេសាទមានទីស្នាក់ការសម្រាប់ទំនាក់ទំនងការងារ និងប្រចាំការ។

ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការសំភារៈ | ចំនួន | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | អាវពោង | ១០ អាវ | ១.៥០០ | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | អាវភ្លៀង | ១០ អាវ | | | | |
| | ភ្លើងហ្វាដាក់តាមកាណូត | ២ | | | | |
| | វិទ្យុទាក់ទង | ៣ | | | | |
| | អាគុយ | ១ | | | | |
| | ឯកសណ្ឋាននិងមួកសម្រាប់ល្បាត | ២០ | | | | |
| | ម៉ាស៊ីនថត | ១ | | | | |
| | ជីភីអេស (GPS) | ១ | | | | |
| | អង្រឹង | ២០ | | | | |
| ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | ទីស្នាក់ការទំហំ ៤មX៦ម | ១ | ២.០០០ | ០១.០៣.២០១៨ | ៣០.១២.២០២០ | |
| ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | ទូកទំហំ ៩ ម X ០,៨ ម | ១ | ១,២០០ | ០១.០១.២០១៨ | ៣០.០១.២០២០ | សម្រាប់១អាណត្តិ |

គ៤-ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត

គោលបំណង ៖- ដើម្បីឱ្យគណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទ ប្រជុំបូកសរុបលទ្ធផលដែលបានអនុវត្តន៍ លើកបញ្ហាផ្សេងៗដែលបានជួបប្រទះ ដើម្បីដំណោះស្រាយ និងលើកផែនការអនុវត្តន៍បន្ត

- ធ្វើរបាយការណ៍ពីលទ្ធផលការងារ ការលំបាក ការងាយស្រួល ទៅអាជ្ញាធរឃុំ ស្រុក ខណ្ឌរដ្ឋបាលជលផលដើម្បីជួយដោះស្រាយ ។

ផលរំពឹងទុក ៖- សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព

- បញ្ហាលំបាកផ្សេងៗ ដែលកើតមាននៅក្នុងសហគមន៍នេសាទ ត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្តន៍ទៅថ្ងៃមុខបន្ត ។

ផែនការប្រជុំគណៈកម្មការ និងក្រុមល្បាត ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | អ្នកចូលរួម | គម្រោងថវិកា(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ | ២០ / ខែ<br>=២០X១២=២៤០<br>១ឆ្នាំ=៧២០ | ២៤.០១.២០១៨ | ២៤.១២.២០២០ | ប្រជុំរៀងរាល់ខែ រយៈពេល ៣ ឆ្នាំ |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ<br>- សមាជិកសហគមន៍<br>-អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋបាលជលផល | ១២០០/ឆ្នាំ | ១២.១២.២០១៨ | ១២.១២.២០២០ | មួយឆ្នាំម្តង |
| ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍ | ៥០០/ឆ្នាំ | ២៥.១២.២០១៨ | ៣០.១២.២០២០ | ៣ឆ្នាំម្តង |

| | | | | | | |
|---|---|---|---|---|---|---|
| | - ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ<br>- សមាជិកសហគមន៍<br>-អាជ្ញាធរមូលដ្ឋាន<br>-រដ្ឋបាលជលផល | | | | | |

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គោលបំណង ៖ - ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទក្នុងសហគមន៍ឱ្យមានប្រសិទ្ធភាព
- សហគមន៍នេសាទមានមធ្យោបាយសម្រាប់ទប់ស្កាត់បទល្មើស ។

ផលរំពឹងទុក ៖ - សហគមន៍នេសាទមានការយាមល្បាតទៀងទាត់
- បទល្មើសនេសាទនៅក្នុងសហគមន៍ ត្រូវបានថយចុះ ។

ផែនការចុះទប់ស្កាត់បទល្មើសនេសាទ ត្រូវបានរៀបចំដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ សំភារៈ | គម្រោងថវិកា (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៥.១-ចុះល្បាតចំនួន ១០ ដង ក្នុង១ ខែនៅរដូវប្រាំង (១០ ដងx៨ ខែX៤ លីត្រ=៣២០លីត្រ) | - ប្រេងសាំងចំនួន ៣២០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៨ លីត្រ | ៤២០ | -គណៈកម្មការសហគមន៍នេសាទ<br>-ក្រុមល្បាតសហគមន៍<br>- ប៉ូលីសប៉ុស្តិ៍<br>- ឆ្មាំទន្លេ | ០១.០១.២០១៨ | ៣០.០៦.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |
| ៥.២-ចុះល្បាតចំនួន ៥ ដងក្នុង១ ខែ នៅរដូវវស្សា (៥ ដងx៤ ខែX៤ លីត្រ=៨០ លីត្រ) | - ប្រេងសាំងចំនួន ៨០ លីត្រ<br>- ប្រេងម៉ាស៊ីន ចំនួន ៤ លីត្រ | ១១០ | | ០១.០៧.២០១៨ | ៣០.១២.២០២០ | ល្បាតរៀងរាល់ឆ្នាំ រយៈពេល ៣ ឆ្នាំ |

គ៦-ផែនការផ្សព្វផ្សាយ

គោលបំណង ៖ ដើម្បីឱ្យសមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងពីឯកសារផ្សេងៗ របស់សហគមន៍ និងប្រកាស អនុក្រឹត្យ និងច្បាប់ផ្សេងដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

ផលរំពឹងទុក ៖ សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព។

ផែនការផ្សព្វផ្សាយច្បាប់ជលផល ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងសហគមន៍នេសាទ | -ឯកសារផ្សព្វផ្សាយ<br>-គ្រូបង្គោល | ៣៥០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល សមាជិកសហគមន៍នេសាទ | ០១.០១.២០១៨ | ០១.០២.២០២០ | រវាងខែ១ និងខែ២ រាល់ឆ្នាំ |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀង ប្រកាសស្តីពីការចុះបញ្ជីសហគមន៍នេសាទនិងផែនទីកន្លែងនេសាទសហគមន៍ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៦.៣-ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រង និងការពារសត្វផ្សោត និងបរិស្ថាន | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍នេសាទ | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២. ២០២០ | |

## គ៧-ផែនការបណ្តុះបណ្តាល

គោលបំណង ៖ ផ្តល់ចំណេះដឹងពីការងាររដ្ឋបាល ការងារធ្វើផែនការ ការងារដឹកនាំ និងនីតិវិធីកសាងឯកសារនានាដល់គណៈកម្មការសហគមន៍នេសាទ។

លទ្ធផលរំពឹងទុក ៖ គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំ ការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។

ផែនការបណ្តុះបណ្តាល ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | -ឯកសារបណ្តុះបណ្តាល<br>-គ្រូបណ្តុះបណ្តាល | ៣៥០ | គណៈកម្មការអាជ្ញាធរមូលដ្ឋានក្រុមល្បាត | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| ៧.៤-បណ្តុះបណ្តាលអំពីការតាមដាន និងវិភាគគុណភាពទឹក | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និងការកសាងសំណុំរឿងបទល្មើសជលផលបឋម | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |

គ៨-ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍

គោលបំណង ៖ ដើម្បីប្រមូលថវិកាពីសមាជិកមកប្រើប្រាស់សម្រាប់ការងារគ្រប់គ្រងសហគមន៍។

លទ្ធផលរំពឹងទុក ៖ សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។

ផែនការចំណូលថវិកាទ្រទ្រង់សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូលសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| ៨.១-ភាគទានពីសមាជិកសហគមន៍ នេសាទដែលទើបនឹងចូលថ្មី | ប្រមូលភាគទានពីសមាជិកដែលចូលថ្មី | ០១.០៦.២០១៨ | ០១.១២.២០២០ | ១០០.០០០ | ១.០០០ រៀល/នាក់ |
| ៨.២-វិភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | ប្រមូលភាគទានប្រចាំពីសមាជិក | ០១.០៦.២០១៨ | ០១.១២.២០២០ | ៣៤២.០០០ | ១.០០០ រៀល/នាក់ រយៈពេល៣ឆ្នាំ |
| ៨.៣- ធ្វើហិបវិភាគទាន តាមកន្លែងទេសចរណ៍, បុណ្យ, វត្ត មន្ទីរបពេទ្យ ។ល។ | ធ្វើហិបវិភាគទាន និងដាក់តាមកន្លែងទេសចរណ៍, បុណ្យ, វត្ត, មន្ទីរពេទ្យ ។ល។ | ០១.០៣.២០១៨ | ០១.០៣.២០២០ | | កិច្ចគាំទ្រពីស្ថាប័នពាក់ពន្ធ័ និងមនុស្សសំខាន់ |

គ៩-ផែនការកែលម្អដែននេសាទ

សំគាល់ ៖ ដោយកន្លែងនេសាទសហគមន៍ស្ថិតនៅតាមដងទន្លេមេគង្គពុំមានផែនការ ត្រូវកែលម្អឡើយ ។

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |

គ១០-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

កំណត់សំគាល់ ៖ ទីតាំងសហគមន៍ស្ថិតនៅក្នុងតំបន់ស្នូលទី៣ ក្នុងឃុំកំពង់ចាម ដែលកំណត់ដោយអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ ពុំអនុញ្ញាតឱ្យធ្វើ វារីវប្បកម្មបែ ឬសីងក្នុងតំបន់ស្នូលនៅរដូវប្រាំង ម៉្យាងវិញទៀតនៅតំបន់នេះ ជាប្រភេទដីមិនគត់ទឹកនៅរដូវប្រាំង ។

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រី | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| | | | | | |

គ១១-ផែនការមុខរបរចិញ្ចឹមជីវិត

គោលបំណង ៖ ដើម្បីធ្វើឱ្យគណៈកម្មការនិងសមាជិកសហគមន៍នេសាទ ទទួលបានប្រាក់ចំណូល និងជីវភាពបានប្រសើរឡើងតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួម ដើម្បីឈានដល់ការកាត់បន្ថយភាពក្រីក្រ និងការនេសាទក្នុងតំបន់អភិរក្សសត្វផ្សោត។

លទ្ធផលរំពឹងទុក ៖ គណៈកម្មការសហគមន៍នេសាទ និងសមាជិកមានមុខរបរ ទទួលបានប្រាក់ចំនូល ជីវភាព ត្រូវបានប្រសើរឡើង និងការធ្វើនេសាទនៅក្នុងតំបន់ស្នូលជាតំបន់អភិរក្សសត្វផ្សោត ត្រូវបានកាត់បន្ថយ ។

ផែនការបង្កើតមុខរបរចម្រុះ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | តម្រូវការ | គម្រោងថវិកា(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | -គ្រូបណ្តុះបណ្តាល<br>- ឯកសារបណ្តុះបណ្តាល<br>- ថវិកាទុន | ៤.០០០ | គ្រូបណ្តុះបណ្តាល គណៈកម្មការ និង សមាជិសហគមន៍ ដែលជាក្រុមគោដៅ ពី១៥ទៅ២០នាក់ | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ១.៥០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង | | ២.០០០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |

### ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តន៍ផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តន៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជាការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹម ត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តន៍ផែនការ
- រៀបចំផែនការអនុវត្តន៍ផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តន៍ផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសម្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តន៍ផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អន្លង់វាលព្រលូងលួងចិត្ត រយៈពេល ៣ ឆ្នាំ (២០១៨ ដល់ ២០២០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(ដុល្លា) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទ ឧបករណ៍នេសាទហាមឃាត់ | - ត្រីមេពូជ និងផ្សោត ត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍<br>- ការនេសាទនៅកន្លែងអភិរក្ស និងឧបករណ៍នេសាទខុសច្បាប់ ត្រូវបានហាមឃាត់។ | ២០០/ឆ្នាំ | អង្គការដៃគូ រដ្ឋបាលជលផលសហគមន៍ | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | | | | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | | | | ០១.០១.២០១៨ | ៣០.១២.២០២០ | |
| គ២-ផែនការការពារកន្លែងអភិរក្សសហ-គមន៍ | ២.១-ស្លាកសញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | - ត្រីមេពូជ និងផ្សោត ត្រូវបានការពារ និងមានការកើនឡើងនៅក្នុងសហគមន៍<br>- ការនេសាទនៅកន្លែងអភិរក្ស ត្រូវបានហាមឃាត់ អ្នកពាក់ព័ន្ធ និងស្គាល់សហគមន៍បានច្បាស់ | ៤០០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ៣០.០៦.២០២០ | រៀងរាល់ឆ្នាំ |
| | ២.២-បោះបង្គោលព្រំប្រទល់សហគមន៍ចំនួន ៤បង្គោល | | ៤០០ | | ០១.០២.២០១៨ | ៣០.០២.២០២០ | |
| | ២.៣-ដាក់បង្គោលព្រំប្រទល់អន្លង់អភិរក្សធ្វើអំពីដែកចំនួន៤មានស្លាកសម្គាល់និងមានទង់ជាតិ | | ៣០០ | | ០១.០៤.១៨ | ៣០.០៤.២០១៨ | |
| គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ | ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | - គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទអាចអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាពខ្ពស់<br>- សហគមន៍នេសាទមានស្នាក់ការសម្រាប់ទំនាក់ទំនងការងារ | ១.៥០០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០២.២០១៨ | ៣០.០២.២០២០ | ប្រចាំឆ្នាំ/ខែ |
| | ៣.២-សាងសង់ទីស្នាក់ការសហគមន៍ | | ២.០០០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| | ៣.៣-កាណូតម៉ាស៊ីន ១៣ សេះ | | ១.២០០ | | ០១.០១.២០១៨ | ៣០.០១.២០១៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | និងប្រចាំការ។ | | | | | |
| គ៤-ផែនការប្រជុំគណៈកម្មការនិងក្រុមល្បាត | ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | -សហគមន៍នេសាទអាចដំណើរការគ្រប់គ្រងមានប្រសិទ្ធភាព។ -បញ្ហាលំបាកផ្សេងដែលកើតមាននៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយ និងលើកទិសដៅអនុវត្តន៍ ។ | ២០/ខែ =២០X១២= x ៣ឆ្នាំ=៧២០ | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍ | ២៤.០១.២០១៨ | ២៤.១២.២០២០ | ប្រជុំរៀងរាល់ខែ |
| | ៤.២-រៀបចំមហាសន្និបាតសហគមន៍ នេសាទប្រចាំឆ្នាំ | | ១២០០/ឆ្នាំ | | ១២.១២.២០១៨ | ១២.១២.២០២០ | មួយឆ្នាំម្តង |
| | ៤.៣-រៀបចំផែនការគ្រប់គ្រងឡើងវិញ | | ៥០០ | | ០១.១១.២០២០ | ៣០.១២.២០២០ | បីឆ្នាំម្តង |
| គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ៥.១-ចុះល្បាតចំនួន ៦ ដង ក្នុង១ខែនៅរដូវប្រាំង(៦ដង/ខែ) | -សហគមន៍នេសាទមានការយាមល្បាតទៀងទាត់។ -បទល្មើសនេសាទនៅក្នុងសហគមន៍ ត្រូវបានថយចុះ ។ | ៤២០ នៅរដូវប្រាំង/ឆ្នាំ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ៣០.០១.២០២០ | |
| | ៥.២-ចុះល្បាតចំនួន ៤ ដងក្នុង១ខែ នៅរដូវវស្សា(៤ដង/ខែ) | | ១១០ នៅរដូវវស្សា/ឆ្នាំ | | ០១.០៧.២០១៨ | ៣០.០៧.២០២០ | |
| គ៦-ផែនការផ្សព្វផ្សាយ | ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងហគមន៍នេសាទ | សមាជិកសហគមន៍នេសាទ អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋានយល់ដឹងហើយចូលរួមគាំទ្រ និងអនុវត្តន៍ឱ្យមានប្រសិទ្ធភាព។ | ៣៥០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងកាសស្តីពីការចុះបញ្ជីសហគមន៍ និងផែនទីកន្លែងនេសាទសហគមន៍ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៦.៣- ផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០២០ | |
| | ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផលនិងប្រកាសពាក់ព័ន្ធផ្សេងៗ | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |
| | ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតនិងបរិស្ថាន | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |
| | ៦.៦-ព្វផ្សាយជ្រើសរើសអ្នកចូល | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០២០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ជាសមាជិកសហគមន៍នេសាទ | | | | | | |
| គ៧-ផែនការបណ្តុះបណ្តាល | ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុនិងរបាយការណ៍ | គណៈកម្មការសហគមន៍នេសាទមានសមត្ថភាពក្នុងការដឹកនាំការគ្រប់គ្រង និងការកសាងឯកសារសំណុំរឿងបទល្មើសជលផល។ | ៣៥០ | អង្គការដៃគូ រដ្ឋបាលជលផល | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| | ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | | ៣៥០ | | ០១.០១.២០១៨ | ០១.០២.២០១៨ | |
| | ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| | ៧.៤-បណ្តុះបណ្តាលអំពីការតាមដាននិងវិភាគគុណភាពទឹក | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| | ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និង ការកសាងសំណុំរឿងបទល្មើសជលផលបឋម | | ៣៥០ | | ០១.១២.២០១៨ | ៣០.១២.២០១៨ | |
| គ៨-ផែនការចំណូលថវិកា | ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបនឹងចូលថ្មី | សហគមន៍នេសាទនឹងមានថវិកាមកទ្រទ្រង់ការងារគ្រប់គ្រងសហគមន៍នេសាទ។ | ២០ | ថវិកាសហគមន៍ | ០១.០១.២០១៨ | ០១.១២.២០២០ | |
| | ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ | | ២០ | | ០១.០១.២០១៨ | ០១.១២.២០២០ | |
| | ៨.៣- ធ្វើបិបរិភាគទានតាមកន្លែងទេសចរណ៍, បុណ្យ, វត្តមន្ទីរពេទ្យ ។ល។ | មានសបុរសជនរិភាគទានថវិកាសម្រាប់សហគមន៍ការពារអភិរក្សត្រីនិងសត្វផ្សោត។ | | | ០១.០២.២០១៨ | ០១.០២.២០២០ | |
| គ១១-ផែនការមុខរបរចិញ្ចឹមជីវិត | ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា | សមាជិកសហគមន៍មានជំនាញមានមុខរបរ និងអាចរកប្រាក់ | ៦០០ | អង្គការដៃគូ រដ្ឋបាលជលផល សហគមន៍ | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |
| | ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ឬក្រុមជួយខ្លួនឯង | | ៦០០ | | ០១.០២.២០១៨ | ០១.០៣.២០២០ | |

<u>តារាងកម្មវិធីការងារ</u>

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | | ២០២០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| **គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១-ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតទំហំ ពេលវេលានិងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | → | | | | | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | |
| ១.២-ដាក់បង្ហាញស្លាកសញ្ញាពីប្រភេទឧបករណ៍នេសាទ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.៣-ចុះត្រួតពិនិត្យការធ្វើនេសាទគ្រប់ប្រភេទ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| **គ២-ផែនការការពារកន្លែងអភិរក្សសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| | |
|---|---|
| ២.១-ដាក់ក្បូនឫស្សីស្លាក សញ្ញាសំគាល់កន្លែងអភិរក្សចំនួន ៥ ស្លាក | |
| ២.២-ដាក់បង្គោលព្រំប្រទល់កន្លែងអភិរក្សចំនួន ៤ បង្គោល | |
| ២.៣-ដាក់លូស៊ីម៉ង់ ៤០ លូ | |
| **គ៣-ផែនការពង្រឹងការគ្រប់គ្រងសហគមន៍នេសាទ** | |
| ៣.១-ពង្រឹងការងារល្បាតក្នុងសហគមន៍ | |
| ៣.២-សាងសង់ទីស្នាក់ការ | |
| ៣.៣-ទិញកាណូត១៣សេះ | |
| **គ៤-ផែនការប្រជុំគណៈ កម្មការនិងក្រុមល្បាត** | |
| ៤.១-ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ | |
| ៤.២-រៀបចំមហាសន្និបាតសហគមន៍នេសាទប្រចាំឆ្នាំ | |
| ៤.៣-រៀបចំផែនការគ្រប់គ្រង | |
| **គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ** | |
| ៥.១-ចុះល្បាតចំនួន ១០ ដងក្នុង១ ខែនៅរដូវប្រាំង | |
| ៥.២-ចុះល្បាតចំនួន ៥ | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ដងក្នុង១ ខែ នៅរដូវវស្សា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **គ៦-ផែនការផ្សព្វផ្សាយ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.១-ផ្សព្វផ្សាយអំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.២-ផ្សព្វផ្សាយអំពីកិច្ចព្រមព្រៀងប្រកាសស្តីពីការចុះបញ្ជីសហគមន៍និងផែនទីកន្លែងនេសាទសហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៣-ព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៤-ផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងប្រកាសពាក់ព័ន្ធផ្សេងៗ | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៥-ផ្សព្វផ្សាយអំពីអនុក្រឹត្យតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតនិង បរិស្ថាន | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| ៦.៦-ផ្សព្វផ្សាយជ្រើសរើសអ្នកចូលជាសមាជិកសហគមន៍ | | | | | | | | | | | | → | | | | | | | | | | | | | | | | | | | | | | | | |
| **គ៧-ផែនការបណ្តុះ បណ្តាល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១-បណ្តុះបណ្តាលអំពីរបៀបសសេរកំណត់ហេតុ និងរបាយការណ៍ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២-បណ្តុះបណ្តាលអំពីការធ្វើផែនការសកម្មភាពការងារ | → | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| |
|---|
| ៧.៣-បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ |
| ៧.៤-បណ្តុះបណ្តាលការតាមដាននិងវិភាគគុណភាពទឹក |
| ៧.៥-បណ្តុះបណ្តាលអំពីនីតិវិធី និង ការកសាងសំណុំរឿងបទល្មើសជលផលបឋម |
| ៧.១-បណ្តុះបណ្តាលអំពីរបៀប សសេរកំណត់ហេតុ និងរបាយការណ៍ |
| **គ៨-ផែនការចំណូល ថវិកា** |
| ៨.១-ភាគទានពីសមាជិកសហគមន៍នេសាទដែលទើបចូលថ្មី |
| ៨.២-ភាគទានរបស់សមាជិកសហគមន៍នេសាទប្រចាំឆ្នាំ |
| ៨.៣- ធ្វើហិបវិភាគទាន តាមកន្លែងទេសចរណ៍, បុណ្យ, វត្តមន្ទីរបពេទ្យ ។ល។ |
| **គ១១-ផែនការមុខរបរចិញ្ចឹមជីវិត** |
| ១១.១-បណ្តុះបណ្តាលវគ្គចិញ្ចឹមជ្រូក មាន់ ទា |
| ១១.២-បណ្តុះបណ្តាលក្រុមបណ្តុះផ្សិតចំបើង |
| ១១.៣-បណ្តុះបណ្តាលក្រុមសន្សំប្រាក់ ឬក្រុមជួយខ្លួនឯង |

លេខ : ០៥១ ...ស.ភ.ត
បានឃើញនិងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ
" ដើម្បីពិនិត្យនិងសម្រួល"
កំពី ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៧
នាយផ្នែករដ្ឋបាលជលផលកំពី

ឃឹម គុល

លេខ : ១៣៥៧
បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

អែន ជាសាន

លេខ : ០៥១/១៧
បានឃើញនិងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលកំពី
" ដើម្បីពិនិត្យនិងសម្រួល"
ឃុំកំពង់ចាម ថ្ងៃទី ១៦ ខែ ១១ ឆ្នាំ២០១៧
មេឃុំកំពង់ចាម

ឈិត_ណាន

លេខ : ០៤៤ ភ.ស.រ.ក្រច
បានឃើញនិងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
" ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"
ក្រចេះ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៨
ប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ

គួយ_ហួត

សូមគោរពជូន
លោកមេឃុំកំពង់ចាម
" ដើម្បីពិនិត្យនិងសម្រួល"
ភូមិអំពិលទឹក ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៧
ប្រធានគណៈកម្មការសហគមន៍នេសាទ
អន្លង់វាលព្រលួងលួងចិត្ត

លេខ : ១៩៦ រស.ក្រច
បានឃើញនិងគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ
" ដើម្បីពិនិត្យនិងសម្រួល"
ក្រចេះ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៧
នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

សៀន គិន